**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
ក្រសួងមហាផ្ទៃ
លេខ ១៤៣៣ ប្រ.ក

# ប្រកាស
# ស្តីពី
# ការប្រើប្រាស់ផ្លាកលេខថ្មីសំគាល់យានជំនិះ និងជលយាននគរបាលជាតិ និងការគ្រប់គ្រងបញ្ជីបណ្ណសំគាល់យានជំនិះគ្រប់ប្រភេទ

## សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញក្រឹត្យលេខ ៦៨ ក្រ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីចរាចរផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- យោងអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការចេញផ្លាកលេខ សំគាល់យានជំនិះ
- តាមសំណើរបស់អគ្គស្នងការនគរបាលជាតិ

## សំរេច

**ប្រការ ១** កំណត់ទូទៅ

១.១. ប្រគល់សិទ្ធិជូន អគ្គស្នងការនគរបាលជាតិ រៀបចំផ្លាស់ប្តូរប័ណ្ណសំគាល់ និងចេញផ្លាកលេខថ្មី យានយន្តនិងជលយានជាកម្មសិទ្ធិរបស់ក្រសួងមហាផ្ទៃ ប្រើប្រាស់ជាមធ្យោបាយ សំរាប់ការងារ ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សង្គម និងត្រូវបូកសរុបរាយការណ៍ជូនក្រសួង ជាទៀងរាល់ខែ ។

១.២. យានយន្តគ្រប់ប្រភេទ ដែលជាកម្មសិទ្ធិរបស់ក្រសួងមហាផ្ទៃមាន រដ្ឋបំពាក់ ក្រសួងចំណាយថវិកាទិញផ្ទាល់ អំណោយពីអង្គការនានា និងសប្បុរសជន ហើយត្រូវបានចុះបញ្ជីសារពើភ័ណ្ឌនៅក្រសួងមហាផ្ទៃ ។

១.៣ យានយន្ត និងជលយាន ដែលត្រូវបានផ្តល់ប័ណ្ណសំគាល់ និង ផ្លាកលេខក្រសួងមហាផ្ទៃ ត្រូវបានបែងចែកប្រភេទដូចខាងក្រោម :

- ប្រភេទទី ១. ទោចក្រយានយន្ត និងត្រីចក្រយានយន្ត
- ប្រភេទទី ២. រថយន្តធុនតូច ( ទេសចរណ៍ )
- ប្រភេទទី ៣. រថយន្តធុន មធ្យម ធ្ងន់ យានយន្តឧបករណ៍ និងប្រយុទ្ធ
- ប្រភេទទី ៤. រ៉ឺម៉ក - ស៊ីមីរ៉ឺម៉ក ( យានសំរាប់ផ្ទុកជាប់ក្បាលរថយន្តសណ្តោង )
- ប្រភេទទី ៥. ជលយាន

**ប្រការ ២. រូបភាពផ្លាកលេខ**

២.១. ផ្លាកលេខយានយន្តមាន ៤ ប្រភេទ និងផ្លាកលេខជលយានមាន ១ ប្រភេទ មានទំហំ មានអក្សរដើមជាអក្សរខ្មែរ មានលេខកូដ លេខសំគាល់ អក្សរឡាតាំង ពណ៌ សញ្ញាសំគាល់ ដូចខាងក្រោម :

ក ១. ផ្លាកលេខសំរាប់ទោចក្រយានយន្ត និងត្រីចក្រយានយន្ត

" <u>នគរបាល 1.0001 POLICE</u> "

ក ២. ផ្លាកលេខសំរាប់រថយន្តធុនតូច ( ទេសចរណ៍ )

" <u>នគរបាល 2.0001 POLICE</u> "

ក ៣. ផ្លាកលេខសំរាប់រថយន្តធុនមធ្យម ធ្ងន់ យានយន្តឧបករណ៍ និងប្រយុទ្ធ

" <u>នគរបាល 3.0001 POLICE</u> "

ក ៤. ផ្លាកលេខសំរាប់ រ៉ឺម៉ក-ស៊ីមីរ៉ឺម៉ក ( យានសំរាប់ផ្ទុកជាប់ក្បាលរថយន្តសណ្តោង )

" <u>នគរបាល 4.0001 POLICE</u> "

ក ៥., ផ្លាកលេខសំរាប់ជលយាន

" <u>នគរបាល 5.0001 POLICE</u> "

ខ <u>ទំហំផ្លាកលេខ :</u>

ខ ១. - ផ្លាកលេខទោចក្រយានយន្ត ត្រីចក្រយានយន្តទំហំ ២០០មម x ១២០មម

ខ ២. - ផ្លាកលេខរថយន្តធុនតូច ( ទេសចរណ៍ ) ខាងមុខ និងខាងក្រោយ ទំហំស្មើគ្នា ៣០៥មម x ១៦០មម

ខ ៣. - ផ្លាកលេខរថយន្តធុនមធ្យម ធុនធំ យានយន្តបរិក្ខារណ៍ និងប្រយុទ្ធ រ៉ឺម៉ក-សឺមីរ៉ឺម៉ក ទំហំ :

- ផ្លាកមុខ ៣៦០មម x ១៩០មម
- ផ្លាកក្រោយ ៣៦០មម x ២២០មម

ខ ៤. - ផ្លាកលេខជលយានមានចំនួនពីរ មានទំហំប៉ុនគ្នា ៣៦០មម x ២២០មម ដាក់នៅសងខាងផ្នែកខាងក្រោមនៃជញ្ជាំងមុខមានកំពស់ពីគែមចំនួន ២០មម ។

គ. តួអក្សរ

គ ១. អក្សរខ្មែរ :

- ទោចក្រយានយន្ត និងត្រីចក្រយានយន្តកំពស់ ២២មម សង្កត់ផុស ។
- រថយន្តធុនតូច ធុនមធ្យម ធុនធំ យានយន្តបរិក្ខារណ៍ និងប្រយុទ្ធ រ៉ឺម៉ក សឺមីរ៉ឺម៉ក និងជលយានកំពស់ ៨៥មម សង្កត់ផុស ។

គ ២. អក្សរឡាតាំង :

- ទោចក្រយានយន្ត និងត្រីចក្រយានយន្ត កំពស់ ៨មម ។
- រថយន្តធុនតូច ធុនមធ្យម ធុនធំ យានយន្តបរិក្ខារណ៍ និងប្រយុទ្ធ សឺមីរ៉ឺម៉ក និង ជលយានកំពស់ ១២មម ។

ឃ. កំពស់លេខ :

- ទោចក្រយានយន្ត និងត្រីចក្រយានយន្ត កំពស់ ៨៥មម ។
- រថយន្តធុនតូច ធុនមធ្យម ធុនធំ យានយន្តបរិក្ខារណ៍ និងប្រយុទ្ធ សឺមីរ៉ឺម៉ក និង ជលយាន កំពស់ ៧០មម ។

ង. ពណ៌ :

ផ្លាកលេខគ្រប់ប្រភេទនៃយានយន្ត និងជលយាននគរបាលជាតិ ជាកម្មសិទ្ធិរបស់ក្រសួង មហាផ្ទៃ មានផ្ទៃពណ៌ ស អក្សរនិងលេខពណ៌ក្រហម មានសញ្ញារាជសីហ៍ សំគាល់ផ្នែកខាងស្តាំ ជ្រុងខាងលើនៃផ្លាក ។

**ប្រការ ៣ : ការទូទាត់លើតំលៃផ្លាកលេខ**

៣.១. សាមុីអង្គភាពនីមួយៗដែលប្រើប្រាស់យានយន្តគ្រប់ប្រភេទចំណុះ អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃមកសុំធ្វើការចុះបញ្ជីផ្តល់ផ្លាកលេខត្រូវស្នើសុំថវិកាពីក្រសួងដោយខ្លួនឯង មកបង់អោយនាយកដ្ឋានជំនាញដើម្បីផលិតជូនតាមតំលៃដូចខាងក្រោម :

- ទោចក្រយានយន្ត និងត្រីចក្រយានយន្ត តំលៃ ៤២.០០០ រៀល
- រថយន្តធុនតូច ( ទេសចរណ៍ ) ផ្លាកលេខចំនួនពីរ ( មុខក្រោយ ) តំលៃ ៩២.៤០០រៀល
- រថយន្តធុនមធ្យម ធុនធ្ងន់ យានយន្តឧបករណ៍ និងប្រយុទ្ធ សីមីរ៉ឺម៉ក និងជលយានផ្លាក ចំនួនពីរ តំលៃ ១១៣.៤០០ រៀល ។
- រូបសញ្ញានគរបាលជាតិ ( រាជសីហ៍ ) ចំនួនមួយតំលៃ ៣៧.៨០០ រៀល ។
- តំលៃខាងលើអាចមានការប្រែប្រួលនិងកំណត់ជាថ្មី តាមអត្រាឡើងចុះនៃវត្ថុធាតុដើម តាមសំណើរបស់អគ្គស្នងការនគរបាលជាតិ ។

**<u>ប្រការ ៤.</u>** <u>លក្ខ័ណ្ឌប្រើប្រាស់</u> :

៤.១. យានយន្ត និងជលយានគ្រប់ប្រភេទ ដែលបំរើអោយអង្គភាពនគរបាលជាតិ ក្នុងប្រភេទដឹកជញ្ជូនកងអង្គរក្ស សង្គ្រោះ បង្កានិងពន្លត់អគ្គីភ័យ រក្សាសណ្តាប់ធ្នាប់សាធារណៈ រក្សាសណ្តាប់ធ្នាប់ចរាចរ បង្កានិងបង្ក្រាបបទល្មើសក្រៅពីផ្លាកលេខដែលបានពាក់ ត្រូវមានរូបសញ្ញានគរបាលជាតិ( រាជសីហ៍) និងមានសរសេរឈ្មោះអង្គភាពប្រើប្រាស់ព្រមទាំងអក្សរឡាតាំង (POLICE) ពីខាងក្រៅជារង្វង់ស្វែងក្របីតាមទំហំសមស្របនៅទ្វារមុខទាំងសងខាងនៃយានយន្ត ។ យានយន្តនិងជលយានទាំងនេះត្រូវបានលាបពណ៌ពិសេស តាមការកំណត់របស់ក្រសួងមហាផ្ទៃ ។

៤.២. ក្រសួងមហាផ្ទៃប្រគល់សិទ្ធិអោយអគ្គស្នងការដ្ឋាននគរបាលជាតិ កំណត់កាលបរិច្ឆេទនៃការផ្លាស់ប្តូរប័ណ្ណសំគាល់ ចេញផ្លាកលេខថ្មីដល់យានយន្តនិងជលយានគ្រប់ប្រភេទ ដូចបានកំណត់ក្នុងប្រការ ១ និង ធ្វើបទដ្ឋានផ្សេងៗទៀតតាមការចាំបាច់ ព្រមទាំងធ្វើការត្រួតពិនិត្យការអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាព ។

៤.៣. អគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវជំរុញកិច្ចសហការជាមួយក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងការពារជាតិអោយបានល្អនិងទាន់ពេលវេលា ក្នុងការប្រមូលពត៌មានទិន្នន័យនៃការផ្តល់ប័ណ្ណសំគាល់យានយន្ត ជលយាននិងផ្លាកលេខ ដូចមានចែងក្នុងមាត្រា ៥ , មាត្រា ៦ នៃអនុក្រឹត្យលេខ៧៧អនក្របក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ដើម្បីបំរើដល់ការគ្រប់គ្រងសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ។

៤.៤. បណ្ណានាយកដ្ឋាន អង្គភាពនានា ស្នងការដ្ឋាននគរបាលគ្រប់ ខេត្ត-ក្រុង ដែលមានបណ្តាមធ្យោបាយដូចបានរៀបរាប់ក្នុងប្រការ ១ ត្រូវធ្វើបែបបទដើម្បីស្នើសុំប័ណ្ណសំគាល់និងផ្លាកលេខយានយន្ត ជលយានតាមគំរូថ្មី ។

៤.៥ ជនណា ប្រើប្រាស់ប័ណ្ណសំគាល់ និងផ្លាកលេខនគរបាលក្លែងក្លាយនឹងត្រូវផ្តន្ទាទោសតាមច្បាប់ ជា

ធរមាន ។

**ប្រការ ៥:** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីខ្លឹមសារដូចមានចែងក្នុងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦:** អគ្គលេខាធិការដ្ឋាន អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និង នគរបាល អភិបាលខេត្ត-ក្រុង ប្រធាននាយកដ្ឋាន អង្គភាពចំណុះ និងស្នងការនគរបាលខេត្ត-ក្រុង មានភារកិច្ចអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានិងឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅភ្នំពេញ,ថ្ងៃទី...១៧...ខែ...១១.....ឆ្នាំ ២០០៥

ស ខេង

[illegible]

**ចំលងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- គ្រប់អភិបាលខេត្ត-ក្រុង
- គ្រប់ស្ថាប័នចំណុះក្រសួងមហាផ្ទៃ
- គ្រប់ស្នងការដ្ឋាននគរបាលខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ